# ទីក្រុងឡុងប៊ិច
# ការគ្រប់គ្រងហិរញ្ញវត្ថុ

## អាជ្ញាប័ណ្ណអាជីវកម្ម

**ផ្នែកអាជ្ញាប័ណ្ណអាជីវកម្ម**ទទួលខុសត្រូវលើការផ្តល់អាជ្ញាប័ណ្ណ និងការអនុញ្ញាតដល់អាជីវកម្មទាំងអស់នៅក្នុងទីក្រុងឡុងប៊ិច ការប្រមូលពន្ធអាជីវកម្ម ពន្ធលើការជួលអគារបណ្តោះអាសន្ន (TOT) សម្រាប់សណ្ឋាគារ លិខិតអនុញ្ញាតសម្រាប់ការប្រកាសអាសន្ន លិខិតអនុញ្ញាតសម្រាប់ការលក់សម្លៀកបំពាក់/របស់ចាស់ៗ និងលិខិតអនុញ្ញាតផ្សេងៗទៀត និងប្រាក់កម្រៃនានា។ អាជ្ញាប័ណ្ណអាជីវកម្មក៏ជួយសម្រួលដល់ដំណើរការចេញលិខិតអនុញ្ញាតសកម្មភាពកំសាន្តសម្រាប់សវនាការ ការដកហូត ការព្យួរ និងសវនាការបណ្តឹងឧទ្ធរណ៍របស់ក្រុមប្រឹក្សាក្រុងផងដែរ។ ផ្នែកនេះបម្រើអតិថិជន និងនិវាសនជនតាមរយៈបញ្ជរ ទូរសព្ទ អ៊ីមែល និងតាមរយៈការស៊ើបអង្កេតនៅតាមមូលដ្ឋាន។

ដើម្បីស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មរបស់អ្នកតាមប្រព័ន្ធអ៊ីនធើណិត ឬដើម្បីទទួលបានចម្លើយសម្រាប់សំណួរនានារបស់អ្នកអំពីការចាប់ផ្តើមអាជីវកម្មនៅទីក្រុងឡុងប៊ិច សូមពិនិត្យមើលធនធាននានានៅលើ វិបផតថលអាជីវកម្ម ថ្មីរបស់យើង។




## ព័ត៌មានស្តីពីអាជ្ញាប័ណ្ណអាជីវកម្មទូទៅ

LBMC ផ្នែក 3.80.210 តម្រូវឲ្យរាល់អាជីវកម្មទាំងអស់ដែលប្រតិបត្តិការនៅក្នុងទីក្រុងឡុងប៊ិចធ្វើការបង់ពន្ធអាជ្ញាប័ណ្ណអាជីវកម្ម។ នៅក្នុងករណីមួយចំនួន ក្រុងអាចតម្រូវឲ្យមានលិខិតអនុញ្ញាតតាមបទប្បញ្ញត្តិ និង/ឬភ័ស្តុតាងនៃអាជ្ញាប័ណ្ណរបស់រដ្ឋ ឬសហព័ន្ធផងដែរ។ មុនពេលចេញអាជ្ញាប័ណ្ណអាជីវកម្ម ប្រភេទអាជីវកម្មមួយចំនួននឹងតម្រូវឲ្យមានការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្ម និង/ឬទីតាំងអាជីវកម្មដែលនឹងត្រូវបានត្រួតពិនិត្យឡើងវិញដោយក្រសួងសេវាអភិវឌ្ឍន៍ អគ្គិភ័យ សុខាភិបាល និង/ឬក្រសួងនគរបាល។ អាជីវកម្មនានាដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់អភិវឌ្ឍន៍អាជីវកម្ម (BIDS) ត្រូវបង់ប្រាក់កម្រៃបន្ថែម។

អ្នកអាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មដោយផ្ទាល់ ឬតាមរយៈសំបុត្រតាមប្រៃសណីយ៍ (ការរឹតត្បិតមួយចំនួនត្រូវបានអនុវត្ត)។ រាល់ពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មទាំងអស់ត្រូវតែមានហត្ថលេខាច្បាប់ដើម។ សំណៅចម្លង អ៊ីមែល និងពាក្យស្នើសុំដែលបានផ្ញើតាមទូរសារនឹងមិនត្រូវបានទទួលយកនោះទេ។

# ទីក្រុងឡុងប៊ិច
# ការគ្រប់គ្រងហិរញ្ញវត្ថុ

[ពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្ម](#)
[សេចក្តីណែនាំអំពីពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្ម](#)

ការបន្តសុពលភាពអាជ្ញាប័ណ្ណអាជីវកម្មត្រូវបានផ្ញើជូនជារៀងរាល់ឆ្នាំ។ ប្រសិនបើអ្នកមិនទទួលបានវិក្កយបត្រទេនោះ វាគឺជាការទទួលខុសត្រូវរបស់ម្ចាស់អាជីវកម្មក្នុងការទូទាត់ថ្លៃសេវាសម្រាប់ការបន្តសុពលភាពប្រចាំឆ្នាំ។ ប្រសិនថ្លៃសេវាសម្រាប់ការបន្តសុពលភាពមិនបានទូទាត់ឱ្យទាន់ពេលវេលា ឬ មិនបានទូទាត់ទេនោះ អាជីវកម្មនឹងមិនទទួលបានអាជ្ញាប័ណ្ណឡើយ និង/ឬអាជីវកម្មនោះអាចទទួលពិន័យ។

**ប្រសិនបើអ្នកឈប់ដំណើរការអាជីវកម្មរបស់អ្នក ឬអ្នកមានបំណងបិទអាជីវកម្មរបស់អ្នកនៅក្នុងទីក្រុងឡុងប៊ិច សូមបំពេញ [ទម្រង់](#) ខាងក្រោម។ សូមចងចាំថា ទីក្រុងនឹងមិនបិទគណនីរបស់អ្នកដោយស្វ័យប្រវត្តិនោះទេ។**

ផ្នែកអាជ្ញាប័ណ្ណអាជីវកម្មត្រួតពិនិត្យប្រតិបត្តិនានាដូចខាងក្រោម៖

### ទម្រង់អាជ្ញាប័ណ្ណអាជីវកម្ម

- [ពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្ម](#)
- [ពាក្យស្នើសុំរបស់អ្នកលក់ក្នុងព្រឹត្តិការណ៍ពិសេស](#)
- [ពាក្យស្នើសុំសម្រាប់ការលក់តាមរដូវកាល](#)
- [ពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់ការប្រកាសអាសន្ន](#)
- [ទម្រង់គណនាពន្ធលើការជួលអគារបណ្តោះអាសន្ន](#)
- [ទម្រង់វាយតម្លៃការអភិវឌ្ឍអាជីវកម្មទេសចរណ៍នៅទីក្រុងឡុងប៊ិច](#)
- [ពាក្យស្នើសុំសម្រាប់ការលក់របស់ចាស់ៗ](#)
- [វិធានប្រតិបត្តិការស្តង់ដារសម្រាប់ការកាន់កាប់លំនៅដ្ឋាន](#)

### ទម្រង់អាជ្ញាប័ណ្ណអាជីវកម្មផ្សេងទៀត

- [តម្លៃអាជ្ញាប័ណ្ណអាជីវកម្ម](#)
- [អាជ្ញាប័ណ្ណអាជីវកម្មនៅក្រៅទម្រង់អាជីវកម្ម](#)
- [សង្កាត់អភិវឌ្ឍន៍អាជីវកម្ម (BIDS)](#)
- [ព័ត៌មានដែលមានសារៈប្រយោជន៍ផ្សេងទៀត](#)
- (ថ្មី!) [កម្មវិធីលើកទឹកចិត្តសម្រាប់អាជ្ញាប័ណ្ណអាជីវកម្មខ្នាតតូច](#)

MAKE A PAYMENT

**សម្គាល់៖** បើសិនអ្នកមានការលំបាកក្នុងការចូលទៅកាន់ពាក្យស្នើសុំទូទាត់ប្រាក់របស់គតិយភាគី កម្មវិធីនេះប្រហែលជាមិនអាចប្រើប្រាស់ជាមួយ Browser របស់អ្នកទេ។ យើងខ្ញុំណែនាំ៖ កំណែ (Version) ទី 10 ឬខ្ពស់ជាងនេះនៃ Internet Explorer, Safari, Chrome ឬ Firefox។ សូមអរគុណ។

## ទីក្រុងឡុងប៊ិច
## ការគ្រប់គ្រងហិរញ្ញវត្ថុ

ផ្នែកអាជ្ញាប័ណ្ណអាជីវកម្មមានទីតាំងស្ថិតនៅក្នុងសាលាក្រុង។

***ទីក្រុងឡុងប៊ិច***
***333  W. Ocean Boulevard, 4th Floor***
***ឡុងប៊ិច CA 90802***

**ម៉ោងសម្រាប់បញ្ជរ៖**

ថ្ងៃច័ន្ទ និងថ្ងៃអង្គារ៖
ម៉ោង 7:30 a.m.  រហូតដល់ម៉ោង 4:00 p.m.

ថ្ងៃពុធ៖
ម៉ោង 8:30 a.m.   រហូតដល់ម៉ោង 4:00 p.m.

ថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ៖
ម៉ោង 7:30 a.m. រហូតដល់ម៉ោង 4:00 p.m.

**ម៉ោងសម្រាប់ទូរសព្ទ ៖**
ថ្ងៃចន្ទដល់ថ្ងៃសុក្រ ម៉ោង 7:30 a.m. រហូតដល់ម៉ោង 4:30 p.m.
**លេខទូរសព្ទ ៖ (562) 570-6211**
**លេខទូរសារ៖ (562) 499-1097**
**អ៊ីមែល ៖** LBBIZ@longbeach.gov

**Brett Yakus**
មន្ត្រីផ្នែកអាជ្ញាប័ណ្ណអាជីវកម្ម

**Gene Rodriguez**
ប្រធានអធិការ

**Jason MacDonald, CPPO**
អ្នកគ្រប់គ្រងការទិញ និងសេវាអាជីវកម្ម

**Alejandra Garcia**
លេខាធិការការិយាល័យ

## ទីក្រុងឡុងប៊ិច
## ការគ្រប់គ្រងហិរញ្ញវត្ថុ

ថ្លៃសេវាសម្រាប់ ADA ដែលតម្រូវដោយរដ្ឋ (SB 1186)
នៅថ្ងៃទី 19 ខែកញ្ញា ឆ្នាំ 2012 អភិបាល Brown បានចុះហត្ថលេខាលើច្បាប់ SB-1186។ ច្បាប់នេះតម្រូវឲ្យមានការបង់ថ្លៃសេវាជូនរដ្ឋចំនួន $1 ដោយអ្នកស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មក្នុងតំបន់ ឬលិខិតូបករណ៍ ឬលិខិតអនុញ្ញាតប្រហាក់ប្រហែល ឬការបន្តសុពលភាព។ គោលបំណងនៃការបង់ថ្លៃសេវានេះ គឺដើម្បីបង្កើនសិទ្ធិទទួលបានការប្រើប្រាស់របស់ជនពិការ និងការអនុលោមតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានការប្រើប្រាស់ដែលពាក់ព័ន្ធនឹងសំណង់ និងអភិវឌ្ឍជនធានអប់រំសម្រាប់អាជីវកម្មដើម្បីជួយសម្រួលដល់ការអនុលោមតាមច្បាប់ស្តីពីពិការភាពរបស់សហព័ន្ធ និងរបស់រដ្ឋ។

យោងតាមច្បាប់សហព័ន្ធ និងច្បាប់រដ្ឋ ការអនុលោមតាមច្បាប់ស្តីពីសិទ្ធិទទួលបានការប្រើប្រាស់របស់ជនពិការ គឺជាការទទួលខុសត្រូវដ៏ធំ និងសំខាន់មួយដែលអនុវត្តចំពោះម្ចាស់អគារ និងអ្នកជួលអគារនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ដែលមានអគារបើកចំហរសម្រាប់សាធារណជន។ អ្នកអាចទទួលបានព័ត៌មានអំពីកាតព្វកិច្ចស្របច្បាប់របស់អ្នក និងវិធីអនុលោមតាមច្បាប់ស្តីពីសិទ្ធិទទួលបានការប្រើប្រាស់របស់ជនពិការនៅទីភ្នាក់ងារនានាដូចខាងក្រោម៖

ផ្នែកស្ថាបត្យកម្មរដ្ឋ
ក្រសួងស្ថាននីតិសម្បទា
គណៈកម្មការសិទ្ធិទទួលបានការប្រើប្រាស់របស់ជនពិការនៃរដ្ឋកាលីហ្វ័រញ៉ា